# កិច្ចការបញ្ចប់មេរៀនទី៩-សិស្សគំរូ

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

សុធា ជាសិស្សគំរូម្នាក់នៅក្នុងសាលារៀន ។

សុធារៀនពូកែ ហើយតែងជាប់ចំណាត់ថ្នាក់ល្អជារៀងរាល់ខែ ។ ក្រៅពីការរៀនសូត្រ សុធាគោរពវិន័យសាលាយ៉ាងខ្ជាប់ខ្ជួន ។ សុធាតែងស្ដាប់ការទូន្មានប្រៀនប្រដៅរបស់អ្នកគ្រូ លោកគ្រូ និងចេះគោរពចាស់ទុំទាំងនៅក្នុងសាលារៀន ក៏ដូចជានៅតាមទីសាធារណៈដែរ ។ ដោយសារមានចិរិយាមារយាទល្អ ទើបគេជ្រើសរើសសុធាជាសិស្សឆ្នើមប្រចាំសាលា និងជាប្រធានក្រុមប្រឹក្សាកុមារប្រចាំសាលារៀនទៀតផង ។

នាយក អ្នកគ្រូ លោកគ្រូ និងមិត្តភក្តិទាំងអស់ ស្រឡាញ់រាប់អានសុធាគ្រប់ៗគ្នា ។

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើនៅក្នុងសាលារៀននេះ សុធាជាសិស្សដូចម្ដេច ?

☐ ក. ជាសិស្សគំរូ ☐ ខ. ជាសិស្សល្អមធ្យម
☐ គ. ជាសិស្សគេចសាលា ☐ ឃ. ជាសិស្សល្អ

២. តើសុធា រៀនជាប់ចំណាត់ថ្នាក់ដូចម្ដេច ?

☐ ក. ខ្សោយ ☐ ខ. មធ្យម
☐ គ. បង្គួរ ☐ ឃ. ល្អ

៣. ក្រៅពីការរៀនសូត្រ តើសុធាជាសិស្សដូចម្ដេច ?

☐ ក. បង្កភាពស្មុគស្មាញក្នុងសាលា ☐ ខ. គោរពវិន័យសាលាយ៉ាងខ្ជាប់ខ្ជួន
☐ គ. មឺង ☐ ឃ. លេងសើចច្រើន

៤. តើវិន័យនាំមកនូវអ្វី ?

☐ ក. អពមង្គល ☐ ខ. បរាជ័យ
☐ គ. សេចក្ដីថ្លៃថ្នូរ ☐ ឃ. ការសប្បាយរីករាយ

៥. ហេតុអ្វីគេជ្រើសរើសសុធាជាសិស្សឆ្នើម និងជាប្រធានក្រុមប្រឹក្សាកុមារ ?

☐ ក. ចេះជួយការងារគ្រូ ☐ ខ. ចូលចិត្តរៀន
☐ គ. ចិរយាមារយាទល្អ ☐ ឃ. រៀនពូកែ

LIVEWORKSHEETS

# សំណេរ

១. ចូរពន្យល់ពាក្យខាងក្រោម ។

- មារយាទ ( )...........................................................................................................។
- វិន័យ ( ) ..........................................................................................................។
- ក្រុមប្រឹក្សាកុមារ ( ) ..............................................................................................។

២. ចូររកវេវចនសព្ទនឹងពាក្យ " ទូន្មាន ស្អប់ " ។

- ទូន្មាន ≠ .............................. ។ • ស្អប់ ≠................................។

៣. ចូររៀនពាក្យ ឬកន្សោមពាក្យខាងក្រោមជាល្បះឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| ថ្លៃថ្នូរ ។ | វិន័យ | សេចក្ដី | នាំ | នូវ | មក |

.........................................................................................................................

| | | | | | |
|---|---|---|---|---|---|
| សុខភាព | អនាម័យ | មក | នាំ | ល្អ ។ | នូវ |

.........................................................................................................................

| | | | | | | |
|---|---|---|---|---|---|---|
| សិស្ស | សុធា | គំរូ | ជា | ម្នាក់ | សាលារៀន ។ | នៅក្នុង |

.........................................................................................................................

៤. ចូរតែងល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។





............................................................ ............................................................

............................................................ ............................................................

............................................................ ............................................................

LIVEWORKSHEETS